<u>**សូមគោរពជូន**</u>

**ឯកឧត្តម ហោ ណាំហុង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ**

**ឯកឧត្តម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ឯកឧត្តមជាទីគោរព!**

**កម្មវត្ថុៈ** ការព្រួយបារម្ភរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិទាក់ទងនឹងសេចក្តីព្រាងច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ។

យើងខ្ញុំទទួលស្គាល់ពីសារៈសំខាន់ ដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តោតលើការពង្រឹងស្ថាប័នអភិបាលកិច្ច និង ការអនុវត្តកំណែទំរង់ដែលមានទិសដៅដើម្បីធានានូវការអភិវឌ្ឍប្រកបដោយនិរន្តភាព ប្រសិទ្ធភាពការកាត់បន្ថយភាពក្រីក្រ និងការប្តេជ្ញាចិត្តដើម្បីឱ្យមានកិច្ចសហប្រតិបត្តិការរឹងមាំជាមួយនឹងគ្រប់ក្រសួង ភ្នាក់ងារ ដៃគូ-អភិវឌ្ឍន៍ ស្ថាប័នឯកជន អង្គការសង្គមស៊ីវិល ព្រមទាំងស្ថាប័នពាក់ព័ន្ធដែលមានចែងក្នុង ឯកសារ គោលន-យោបាយសំខាន់ៗដូចជា “ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ” ព្រមទាំង “យុទ្ធសាស្ត្រចតុកោណ” សហគម អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ គឺជាដៃគូប្តូរផ្តាច់ដែលបានកំពុងខិតខំប្រឹងប្រែងអភិវឌ្ឍន៍ប្រទេសកម្ពុជាអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ។ ដូចនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នភាពឆ្នាំ ២០០៩ បានកំណត់ថា “សង្គមស៊ីវិលគឺជាដៃគូសំខាន់ ហើយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដើរតួនាទីសំខាន់ និងយ៉ាងសកម្មក្នុងកិច្ចខំប្រឹងប្រែងអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ព្រមទាំងការលើកកម្ពស់ផ្នែកប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស” ។

ក្នុងគោលបំណងបម្រើឱ្យផលប្រយោជន៍រួមក្នុងការអភិវឌ្ឍន៍រយៈពេលវែងរបស់ប្រទេសកម្ពុជា យើងខ្ញុំជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលមានហត្ថលេខីខាងក្រោម មានកិត្តិយសដាក់ជូននូវមតិយោបល់ដូចខាងក្រោមនេះ សូមសំដែងនូវក្តីព្រួយបារម្ភលើផលប៉ះពាល់ដែលទំនងនឹងកើតមាននៃសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ហើយស្ម័គ្រចិត្តផ្តល់នូវជំនួយគាំទ្រក្នុងដំណើរការសេចក្តីព្រាងច្បាប់ថ្មី ដែលលើកកម្ពស់សង្គមស៊ីវិល។ ការព្រួយបារម្ភរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកគឺមិនត្រឹមតែផ្អែកលើសារៈសំខាន់ជាក់លាក់ដើម្បីការអភិវឌ្ឍន៍សង្គមកម្ពុជានោះទេ ប៉ុន្តែក៏ផ្អែកលើទំនាក់ទំនងជាមួយនឹងដៃគូ ក្នុងការ

ផ្តល់ជូននូវជំនួយផ្នែកមនុស្សធម៌ និងផ្តល់ជូននូវសេវាចាំបាច់នានា ។ សមាគម និងអង្គការទាំងនោះគឺជាតួអង្គសំខាន់ក្នុងការអភិវឌ្ឍន៍សង្គម ការបង្កើតដៃគូជាមួយនឹងរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការផ្តល់ជំនួយនានា។ ប្រសិនបើអង្គការទាំងនោះមានភាពទន់ខ្សោយ កម្មវិធីរបស់យើងខ្ញុំ ព្រមទាំងប្រជាជនកម្ពុជា នឹងទទួលរងនូវភ័យហានិភ័យ។

ជំហរនៃសេចក្តីព្រាងច្បាប់ធ្វើឱនភាពដល់គោលបំណងចំបងនៃច្បាប់នេះ "ដើម្បីលើកកម្ពស់ការអនុវត្តសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរក្នុងការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដើម្បីរួមគ្នាការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងការពារផលប្រយោជន៍សាធារណៈ" (មាត្រា ២)។ ការអនុញ្ញាតឱ្យមានឆន្ទានុសិទ្ធិបកស្រាយគ្មានដែនកំណត់ ហើយដែលមានលក្ខណៈរឹតបន្តឹង និងស្រពិចស្រពិលក្នុងសេចក្តីព្រាងច្បាប់នេះ នឹងធ្វើឱ្យខូចប្រយោជន៍ជាជាងផ្តល់ចំណុចល្អដល់សមាគម អង្គការមិនមែនរដ្ឋាភិបាល និងប្រជាជនកម្ពុជា។ លើសពីនេះទៀត សេចក្តីព្រាងច្បាប់នេះមិនស្របទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នទុកជាច្បាប់របស់ខ្លួន ។

មាត្រា ៦ ចែងថា សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសម្ព័ន្ធក្នុងស្រុក ដែលមិនបានចុះបញ្ជីគឺមិនស្របច្បាប់ ហើយមិនត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពនោះទេ។ លើសពីនេះទៀត ទោះបីជាអង្គការដែលធ្វើសកម្មភាពដើម្បី "ប្រយោជន៍សាធារណៈ" (មាត្រា ៤) ដែលទទួលស្គាល់ក្រោមច្បាប់នេះ ប៉ុន្តែគ្មានចំណុចណាដែលកំណត់និយមន័យនៃពាក្យ "ប្រយោជន៍សាធារណៈ" នោះទេ។ បទប្បញ្ញត្តិ និងភាពស្រពិចស្រពិលទាំងនេះធ្វើឱ្យមានភាពមិនច្បាស់លាស់ ថាតើមន្ត្រីរបស់រដ្ឋាភិបាលនឹងទទួលស្គាល់សកម្មភាពតស៊ូមតិដែលជួនកាលទាក់ទងនឹងការបញ្ចេញមតិពីជំហរខ្វែងគំនិតគ្នាលើគោលនយោបាយរបស់រដ្ឋាភិបាល គឺជាផលប្រយោជន៍សាធារណៈឬយ៉ាងណា។ នាពេលបច្ចុប្បន្ន អង្គការមិនមែនរដ្ឋាភិបាលមានជំហរជាអ្នកតស៊ូមតិដើម្បីការពារសិទ្ធិដីធ្លី ផ្នែកសិទ្ធិមនុស្សផ្សេងៗទៀត ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សបរិស្ថាន ហើយនិងបញ្ហាផ្សេងៗទៀតដែលមានសារៈ-សំខាន់ដល់សុខមាលភាពរបស់ប្រជាជនកម្ពុជា។

ប្រទេសកម្ពុជាគឺជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមាត្រា ២២ ធានាឱ្យមានសិទ្ធិចូលរួមជាសមាគម ហើយកំណត់ពីលក្ខខណ្ឌដែលរដ្ឋភាគីអាចដាក់ការអនុវត្តសិទ្ធិនេះលើប្រជា-ពលរដ្ឋ រួមទាំងតម្រូវការសម្រាប់ការចុះបញ្ជី។ មជ្ឈមណ្ឌលអន្តរជាតិដើម្បីនីតិមិនយកប្រាក់ចំណេញ (ICNL) បានពិនិត្យមើលសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅពេលចេញជាសាធារណៈក្នុងខែធ្នូ ឆ្នាំ ២០១០ ការវិភាគរបស់ (ICNL) ត្រូវបានរាយការណ៍ដោយ សេចក្តីសម្រេចរបស់ គណៈកម្មការសិទ្ធិមនុស្ស ICCPR ដែលបញ្ជាក់ថា "រដ្ឋទាំងឡាយដែលប្រើប្រាស់ប្រព័ន្ធចុះបញ្ជីត្រូវធានាថា កិច្ចការនោះពិតជាអាចឈានទៅដល់នីតិវិធី ច្បាស់លាស់ ឆាប់រហ័ស មិនទាក់ទងនឹងនយោបាយ និងមិនមានតម្លៃថ្លៃ ។ អង្គភាពចុះបញ្ជីគួរតែដឹកនាំដោយមានបទដ្ឋានច្បាស់លាស់ ហើយគួរត្រូវបានរឹតបន្តឹងពីការធ្វើសេចក្តីសម្រេចនានាដោយបំពាន"។ ដោយការអនុវត្តបទដ្ឋាននេះ ICNL សន្និដ្ឋានថា "ភាពចន្លោះប្រហោង និងចំណុចនានាដែលបាន

កំណត់ហេតុផលសំរាប់បដិសេធការចុះបញ្ជី ” របស់សេចក្តីច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល ធ្វើឱ្យមានភាពចុះខ្សោយនូវតំលាភាពនៃដំណើរការនេះ ។

សេចក្តីព្រាងច្បាប់ ខែ ធ្នូ ដែល ICNL បានពិនិត្យមើល តម្រូវថា រាជរដ្ឋាភិបាលជូនដំណឹងដល់អ្នកដាក់ពាក្យសុំចុះបញ្ជីឱ្យកែប្រែចំណុចខ្វះខាតនៅក្នុងពាក្យសុំ ហើយផ្តល់ឱ្យមានឱកាសក្នុងការកែតម្រូវ ។ ហើយក៏មានចែងនូវការប្តឹងជំទាស់លើសេចក្តីសម្រេចដែលមានភាពចម្រូងចម្រាស់។ យន្តការដែលបានផ្តល់កិច្ចការពារពីសេចក្តីសម្រេចនានាដែលមានលក្ខណៈបំពានទាំងនោះត្រូវបានដកចេញ។ ក្រោមសេចក្តីព្រាងបច្ចុប្បន្ន ការឆ្លើយតបរបស់រាជរដ្ឋាភិបាលលើពាក្យសុំចុះបញ្ជីគឺមានតែ “ ព្រមទទួលឬ មិនព្រមទទួលចុះបញ្ជី ” តែប៉ុណ្ណោះ ( មាត្រា ១៧) ។

ICNL ក៏បានកំណត់ទៀតថា “តម្រូវការកាតព្វកិច្ចចុះបញ្ជីនៃសេចក្តីព្រាងច្បាប់ធ្វើឱ្យមានការរឹតបន្តឹងលើសេរីភាពចូលរួមជាសមាគម ក្រោមមាត្រា ២២ នៃ កតិកាសញ្ញា ICCPR ។ ” សំរាប់អង្គការអន្តរជាតិដែលមានហត្ថលេខីខាងក្រោមនេះ ក្របខណ្ឌសម្រាប់ចុះបញ្ជីដូចជាមិនត្រឹមតែប្រឆាំងនឹងបទដ្ឋានគតិយុត្តអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នទុកជាច្បាប់របស់ខ្លួននោះទេ ប៉ុន្តែក៏ប្រឆាំងនឹងគោលបំណងនៃការលើកកម្ពស់ “ការអនុវត្តសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក” ជាគោលបំណងចំបងដែលបានចែងនៃសេចក្តីព្រាងច្បាប់ ។

បទប្បញ្ញត្តិដ៏ទៃទៀតបង្ហាញពីការព្រួយបារម្ភ ។ មាត្រា ៥៤ អនុញ្ញាតឱ្យរដ្ឋាភិបាលផ្តន្ទាទោស សមាគម និងអង្គការមិនមែនរដ្ឋាភិបាលណាដែលអនុវត្តមិនត្រឹមត្រូវតាមលក្ខន្តិកៈ ឬអនុស្សរណៈ ។ បទប្បញ្ញត្តិនេះ មិនបានពន្យល់ពីលក្ខខណ្ឌដើម្បីកំណត់ថាការអនុវត្តមិនត្រឹមត្រូវណាដែលមានលក្ខណៈ “ធ្ងន់ធ្ងរ ” តើនរណាជាអ្នកកំណត់ចំណុចនេះ តើនរណាជាអ្នកផ្តន្ទាទោស ឬថាតើអង្គការនោះមានឱកាសប្តឹងជំទាស់ ឬចូលរួមសវនាការយ៉ាងណា ។

អង្គការក្នុងស្រុក និងអង្គការអន្តរជាតិដែលធ្វើការជាមួយនឹងក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ យើងខ្ញុំទាំងអស់គ្នាបន្តនូវសេចក្តីគោរពរាប់អានជាដៃគូដែលផ្តល់តម្លៃឱ្យគ្នា ក្នុងកិច្ចខំប្រឹងប្រែងដើម្បីធ្វើឱ្យសេចក្តីព្រាងច្បាប់មានភាពល្អប្រសើរឡើង ។ គោលបំណងរបស់យើងខ្ញុំគឺដើម្បីលើកកម្ពស់សង្គមស៊ីវិល ហើយយើងខ្ញុំសូមសំណូមពរឱ្យមានការចុះបញ្ជីដោយលក្ខណៈស្ម័គ្រចិត្ត ដែលអាចគាំទ្រនូវគោលបំណងជាវិជ្ជមាននៃមាត្រា ២ ។ សំណើទាំងអស់នេះមិនត្រូវបានទទួលយកនោះទេ ។ លើសពីនេះ ទៅទៀតនៅពេលដែលមានការកែប្រែនេះ វានឹងបានសម្រាលបន្ទុកដល់កិច្ចការរដ្ឋបាលរបស់រដ្ឋាភិបាល ចំណុចទាំងនេះគឺជាអ្វីដែលយើងមិនអាចគិតដល់ក្នុងការប្រៀបធៀបទៅនឹងចំណុចចន្លោះប្រហោងឱ្យបានស៊ីជម្រៅ ក្នុងសេចក្តីព្រាងច្បាប់ អាចមានភាពអាក្រក់ជាងមុន ។

មកដល់ពេលនេះការចូលរួមរបស់យើងខ្ញុំត្រូវបរាជ័យ ។ បើទោះបីជាមានបណងល្អដែលមានចែងក្នុងមាត្រា ២ ក៏ដោយ ក៏សេចក្តីព្រាងច្បាប់នេះនៅមានពីបទប្បញ្ញត្តិជាច្រើនដែលបង្អាក់ និងគ្រប់គ្រងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាជាងការលើកកម្ពស់ និងកិច្ចការពារសមាគម និងអង្គការទាំងនោះ ។ លើសពីនេះទៅទៀត សេចក្តីព្រាងបច្ចុប្បន្នមានបញ្ហាសំខាន់ផ្សេងៗទៀត ហើយមិនបានកំណត់នីតិវិធីឱ្យបានច្បាស់លាស់

ដែលធ្វើឱ្យមានការភ័ន្តច្រឡំផ្នែករដ្ឋបាល និងអំពើពុករលួយ ហើយផ្តល់ផលប៉ះពាល់ដ៏ចម្រូងចម្រាស លើកម្មវិធីដែលយើងខ្ញុំអនុវត្តក្នុងភាពជាដៃគូជាមួយនឹង សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ក្នុងនាមជាអ្នកផ្តល់ជំនួយ និងដៃគូអភិវឌ្ឍន៍ ហើយនិងរាជរដ្ឋាភិបាលកម្ពុជា ។ ភាពខូចខាតដល់សមាគម និងអង្គការទាំងនេះនឹងប៉ះពាល់ដល់កម្មវិធីជំនួយរបស់ម្ចាស់ជំនួយ ហើយជាពិសេសទៅទៀតនោះ គឺការអភិវឌ្ឍន៍ប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជា ។

ដៃគូអភិវឌ្ឍន៍ បានបង្ហាញពីការព្រួយបារម្ភជាសាធារណៈអំពីផលប៉ះពាល់អាចកើតមាននៃសេចក្តីព្រាងលើសកម្មភាពស្របច្បាប់របស់អង្គការសង្គមស៊ីវិល ។ យើងខ្ញុំរំពឹងទុកជាមុនថាម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀតអាចចូលរួមក្នុងការថ្លែងជាសាធារណៈនូវបញ្ហាទាំងអស់នេះ ។

យើងខ្ញុំសូមអំពាវនាវដល់ដៃគូការងារនៅក្នុងក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងមន្ត្រីនានាដែលអាចកំពុងពិចារណាលើសេចក្តីព្រាងនេះ ឱ្យបញ្ឈប់ដំណើរការដែលឆ្ពោះទៅការអនុម័ត រហូតដល់មានការសរសេរឡើងវិញនូវខ្លឹមសារដែលផ្តោតលើចំណុចព្រួយបារម្ភដែលបានកំណត់ខាងលើ ។ យើងខ្ញុំសូមផ្តល់ជំនួយគាំទ្រពេញលេញ ដើម្បីឱ្យមានការកែសម្រួលឡើងវិញឱ្យស្របទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយនិងគោលបំណងនៃមាត្រា ២ ដើម្បី “លើកកម្ពស់ការអនុវត្តសិទ្ធិសេរីភាព របស់ប្រជាពលរដ្ឋខ្មែរក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ ” ដែលទាំងនេះគឺជាច្បាប់ចែងអំពីការចុះបញ្ជីដោយស្ម័គ្រចិត្ត ហើយដែលគាំទ្រដល់តួនាទីរបស់សង្គមស៊ីវិលយ៉ាងពេញ-លេញក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ។

សូម **ឯកឧត្តម** ទទួលនូវសំណើរកែប្រែនេះសារជាថ្មីក្រោមគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់។

1. ActionAid Cambodia
2. Aide et Action International
3. Amici dei Bambini (Ai. Bi.)
4. Association of School Aid in Cambodia (ASAC)
5. Australian People for Health, Education and Development Abroad (APHEDA)
6. Baptist Missionary Association of the Philippines (BMAP)
7. Bridges Across Borders Cambodia
8. Cambodia International Education Support Foundation (CIESF)
9. Cambodia Mines-remove Campaign (CMC)

10. Cambodian Traditional Medicine Organization NGO (NGO-CaTMO)

11. CARE

12. Centre on Housing Rights and Evictions (COHRE)

13. Cesvi

14. ChildFund

15. Christian Aid

16. Concern

17. C-Rights

18. DanChurchAid

19. Diakonia

20. DTW Organization

21. Educational Supporting Center "KIZUNA" (ESC)

22. EWMI-PRAJ

23. Forum Syd

24. Golden Children/Sovann Komar-Cambodia

25. Good Earth Japan (GEJ)

26. Health Unlimited

27. Heinrich Böll Foundation

28. IDE

29. Ideal Family Federation

30. International Volunteers of Yamagata (IVY)

31. Istituto per la Cooperazione allo Sviluppo

32. Japan International Volunteer Center (JVC)

33. Japan Lay Missionary Movement (JLMM)

34. Japan Mine Action Service (JMAS)

35. Japan Team Young Human Power (JHP)

36. Live & Learn Environmental Education International

37. Medical Teams International

38. Mekong Plus

39. Mennonite Central Committee

40. Mercy Teams International

41. NDI

42. NPO / NGO Hearts of Gold

43. Oxfam

44. PACT Cambodia

45. People in Need

46. People's Forum on Cambodia, Japan (PEFOC,J)

47. PH - Japan Foundation (PHJ)

48. PSI

49. Pure Water, Hygiene and Literacy Project

50. Save the Children Australia

51. Save the Children Norway

52. Servants to Asia's Urban Poor, Cambodia

53. Services for the Health in Asian & African Regions (SHARE)

54. Shanti Volunteer Association (SVA)

55. SNV Netherlands Development Organisation

56. The Asia Foundation

57. Union Aid Abroad - Australian People for Health, Education and Development Abroad (APHEDA)

58. Veterans International

59. Volunteer Service Abroad

60. VSO

61. Welthungerhilfe

62. World Vision